នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Jul-2014, 10:37
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រពីលើចំនួនកំណត់សម្រាប់ធ្វើយុត្តិកម្មលើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

# សំណើ

១. កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញ "ដីកាបង្គាប់របស់ខ្លួនឲ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការជំនុំជម្រះក្តី លើសំណុំរឿងលេខ០០២/០២"[1] និងបានបង្គាប់ឲ្យភាគីនានាដាក់នូវបញ្ជីសាក្សី, អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើងសម្រាប់សំណុំរឿងលេខ០០២/០២[2]។ អង្គជំនុំជម្រះថែមទាំងបានថ្លែងថា៖"ដីកាបច្ចុប្បន្ននេះមិនអនុញ្ញាតឲ្យភាគីនានាដាក់បន្ថែមសាក្សី, អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីលើនេះទៀតទេ។ ប៉ុន្តែពាក្យសុំណាមួយដើម្បីស្តាប់ចម្លើយបុគ្គល ត្រូវតែដាក់ឲ្យស្របតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង"[3]។

២. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ ភាគីនានាបានរួមគ្នាដាក់សំណើមួយសុំការបញ្ជាក់បំភ្លឺទៅអង្គជំនុំជម្រះសាលាដំបូង លើកថា វិធាន៨៧(៤) គួរអនុវត្តសម្រាប់តែទៅលើភស្តុតាងប៉ុណ្ណោះ រួមមានភស្តុតាងជាសក្ខីកម្មទាំងឡាយដែលបានស្នើឡើងបន្ទាប់ពីសវនាការបឋមក្នុងសំណុំរឿងលេខ០០២/០២ ជាជាងទៅលើភស្តុតាងទាំងឡាយដែលបានស្នើឡើង នៅក្រោយពេលសវនាការបឋមក្នុងសំណុំរឿងលេខ០០២/០១ កាលពីក្នុងខែមិថុនា ឆ្នាំ២០១១[4]។

៣. នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង០០២/០២[5]របស់ខ្លួន ដែលរួមបញ្ចូលមនុស្ស៣៥នាក់[6] មិនបានស្នើនៅមុនពេលចាប់ផ្តើមនៃសំណុំរឿង០០២/០១។

---

[1] ឯកសារលេខ **E305** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿងលេខ០០២/០២, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤។

[2] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១។

[3] *ដូចគ្នានឹងខាងលើ*។

[4] ឯកសារលេខ **E307** សំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤)នៅក្នុងសំណុំរឿងលេខ០០២/០២, ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

[5] **E305/6** បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខ០០២/០២, ៩ ឧសភា ២០១៤។

[6] តួលេខនេះមិនរាប់បញ្ចូលបុគ្គលដែលបានចុះបញ្ជីជា "សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីបម្រុង" នៅក្នុងឧបសម្ព័ន្ធ III (ក) ទេ។ **E305/6.5** បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបម្រុង និងសេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពរបស់សហព្រះរាជអាជ្ញា, ៩ ឧសភា ២០១៤។.

៤. នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញ "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) (E307) និងសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (E305/3)"[7] ("សេចក្តីសម្រេច")។ ក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធាន៨៧(៤) ត្រូវអនុវត្តបានចំពោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើងទាំងអស់ មិនបានស្នើសុំនៅមុនពេលចាប់ផ្តើមសំណុំរឿង០០២/០១[8]។

៥. ជាលទ្ធផលនៃសេចក្តីសម្រេចនេះ សហព្រះរាជអាជ្ញាបានរៀបចំសំណើ អនុលោមតាមវិធាន៨៧(៤) សម្រាប់បុគ្គលម្នាក់ៗ ក្នុងចំណោមបុគ្គលទាំង៣៥(សាមសិបប្រាំ)នាក់ ដែលបានស្នើឱ្យមកផ្តល់ភស្តុតាងសក្ខីកម្ម ដែលមិនបានបញ្ចូលនៅក្នុងសំណើនានា មុនពេលចាប់ផ្តើមសំណុំរឿង០០២/០១។ យ៉ាងណាក៏ដោយ ដោយសារតែសំណើនានាត្រូវបានដាក់បញ្ចូលគ្នាជាសំណើតែមួយ មានរួមបុគ្គលទាំង៣៥(សាមសិបប្រាំ)នាក់ ដោយមិនធ្វើការលើកឡើងចំបុគ្គលម្នាក់ៗនៅក្នុងសំណើដាច់ដោយឡែក បទដ្ឋានស្តីពីការកំណត់ចំនួន១៥(ដប់ប្រាំ)ទំព័រ[9] ជាភាសាអង់គ្លេស គឺមិនគ្រប់គ្រាន់ទេ ក្នុងការផ្តល់នូវការពន្យល់មួយឱ្យបានពិស្តារគ្រប់គ្រាន់ ជូនដល់អង្គជំនុំជម្រះសាលាដំបូង អំពីកត្តាផ្សេងៗដែលធ្វើយុត្តិកម្មលើសាក្សីម្នាក់ៗ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតដើម្បីដាក់នូវឯកសារដែលមានចំនួន៤៥(សែសិបប្រាំ)ទំព័រ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |

[7] **E307/1** សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព, ១១ មិថុនា ២០១៤។

[8] *ក្នុងឯកសារដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី៥។

[9] *សូមអាន* សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៨, ការដាក់ឯកសារនៅចំពោះមុខ អវតក, មាត្រា៥.១។